ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន

លេខៈ ៦១៤/ន.៣ ២០១៥

# សេចក្ដីប្រកាសជូនពត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្ដម នាយឧត្ដមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ ឯកឧត្ដមនាយឧត្ដមសេនីយ៍ Chang Wanquan រដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន អមដំណើរដោយគណៈប្រតិភូក្រសួងការពារជាតិនៃកងទ័ពរំដោះប្រជាជនចិន នឹងមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជារយៈពេល៤ថ្ងៃពីថ្ងៃទី០៥ ដល់ទី០៨ ខែវិច្ឆកា ឆ្នាំ២០១៥។

ឯកឧត្ដមនាយឧត្ដមសេនីយ៍ Chang Wanguan ព្រមទាំងគណៈប្រតិភូ គ្រោងនឹងជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្ដមនាយឧត្ដមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់មកថ្នាក់ដឹកនាំក្រសួងការពារជាតិទាំងពីរ នឹងចូលរួមជាអធិបតីភាពក្នុងពិធីចុះហត្ថលេខារវាងឯកឧត្ដមនាយឧត្ដមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សានាយកខុទ្ទការល័យឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសជាមួយ ឯក ឧត្ដម ឧត្ដមនាវី Quan You Fei អគ្គនាយក អគ្គនាយកដ្ឋានកិច្ចការបរទេសក្រសួងការពារជាតិចិននៅព្រឹកថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៥។

នៅរសៀលថ្ងៃដដែលនោះឯកឧត្ដមនាយឧត្ដមសេនីយ៍ Chang Wanguan នឹងអញ្ជើញចូលជួបសំដែងការគួរសមជាមួយ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់មកនៅព្រឹកថ្ងៃទី០៧ ខែវិច្ឆិកា ឯកឧត្ដមនាយឧត្ដមសេនីយ៍ Chang Wanguan ព្រមទាំងគណៈប្រតិភូ គ្រោងនឹងទៅទស្សនា វិទ្យាស្ថានកងទ័ពជើងគោក និងរសៀលនាថ្ងៃដដែលនោះដែរឯកឧត្ដមនាយឧត្ដមសេនីយ៍ Chang Wanguan ព្រមទាំងគណៈប្រតិភូបន្តដំណើរទៅទស្សនាប្រសាទអង្គរវត្តក្នុងខេត្តសៀមរាប មុនពេលធ្វើមាតុភូមិនិវត្តន៍វិញ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

ភ្នំពេញ, ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៥